USAID | CAMBODIA
FROM THE AMERICAN PEOPLE

DEVELOPMENT INNOVATIONS

## ករណីជោគជ័យ

# បណ្ណាល័យឌីជីថលជួយសម្រួលដល់ការទទួលបានព័ត៌មាននៅជនបទ



*Aide et Action* កម្ពុជាពង្រឹងគុណភាពនិងវិសាលភាពនៃសម្ភារៈអប់រំសម្រាប់ប្រជាជនកម្ពុជា ជាពិសេសក្រុមជនជាតិដើមភាគតិចនិងនៅតាមតំបន់ជនបទ។
ប្រភពរូបភាព: *Development Innovations*

*"កាលពីមុន សិស្សបឋមសិក្សាជាច្រើនមិនចង់មករៀនហើយឪពុកម្តាយរបស់ពួកគាត់ត្រូវតែបង្ខំពួកគាត់មកសាលាជារៀងរាល់ថ្ងៃ។ ប៉ុន្តែអ្វីៗបានផ្លាស់ប្តូរចាប់ពីពេលដែលមានបណ្ណាល័យនេះនៅក្នុងសាលា បណ្ណាល័យនេះបានទាក់ទាញឲ្យសិស្សមករៀនបានទៀងទាត់ជាងមុន និងបានជួយជំរុញឲ្យពួកគាត់ចូលចិត្តការសិក្សា។"*
*- លោក ស្រី វីរៈ នាយកសាលាបឋមសិក្សាក្រូច*

ក្នុងចំណោមក្រុមប្រជាជនងាយរងគ្រោះ កុមារតែងតែជួបប្រទះឧបសគ្គក្នុងការទទួលបានការអប់រំ ដោយសារតែតម្រូវការជាក់លាក់របស់ពួកគាត់មិនត្រូវបានគេយកចិត្តទុកដាក់។ នៅប្រទេសកម្ពុជា កុមារជនជាតិដើមភាគតិចជួបប្រទះបញ្ហាស្មុគស្មាញមួយកម្រិតទៀតនៅពេលដែលកម្មវិធីសិក្សានៅសាលាមិនសមស្របជាមួយនឹងភាសានិងវប្បធម៌របស់ពួកគាត់ ពីព្រោះកុមារទាំងនេះមិនស្ទាត់ជំនាញក្នុងការប្រើប្រាស់ភាសាខ្មែរដែលជាភាសាតែមួយគត់ដែលត្រូវបានប្រើប្រាស់នៅក្នុងឯកសារអប់រំនៅសាលា។ មុនពេលដែលកុមារទាំងនេះអាចរៀនភាសាទីពីរបានស្ទាត់ជំនាញ ពួកគាត់ត្រូវការរៀនភាសាកំណើតរបស់គាត់ជាមុនសិន។

ដោយមូលហេតុនេះហើយទើប អង្គការ Aide et Action កម្ពុជា (AEA) បាននឹងកំពុងតែជួយសម្រួលដល់ការបង្កើតឯកសារអប់រំដែលមានជាភាសាកំណើតសម្រាប់គ្រូបង្រៀននិងសិស្សជនជាតិដើមភាគតិចនៅខេត្តមណ្ឌលគិរីនិងរតនគិរី។ ចាប់ពីឆ្នាំ២០១៧មក នៅក្នុងផ្នែកមួយនៃកម្មវិធី Khmer រៀនអាន គម្រោង Development Innovations បានគាំទ្រ AEA ដើម្បីបង្កើតខ្លឹមសារចម្រុះ នៅបណ្ណាល័យទំនើបតាមសាលាបឋមសិក្សាគោលដៅចំនួន៧ ។ បណ្ណាល័យឌីជីថលទាំងនេះបានបំពាក់នូវ ទូរទស្សន៍ ទូរស័ព្ទថាប្លែត (tablet) និងសម្ភារៈសិក្សាមានជារូបភាពនិងសំឡេងច្រើនភាសា ដែលផ្ទុកនូវមាតិកាអប់រំថ្មីៗជាភាសាជនជាតិភាគតិច។ បណ្ណាល័យទាំងនេះក៏បានក្លាយជាកន្លែងសិក្សាថ្មីដែលសិស្សនិមួយៗអាចទទួលបានការអប់រំជាភាសាកំណើតរបស់ខ្លួន និងឯកសារសិក្សាផ្សេងៗដែលផលិតក្នុងស្រុកសម្រាប់ពួកគាត់។ ចាប់តាំងពីការបង្កើតបណ្ណាល័យឌីជីថលនេះមក សិស្សជាច្រើនបានចាប់ផ្តើមប្រើប្រាស់ឯកសារសិក្សាដែលពួកគាត់ទទួលបាន។

គ្រូបង្រៀន អ្នកគ្រប់គ្រង និងសិស្សានុសិស្សពេញចិត្តនឹងបណ្ណាល័យឌីជីថលនៅក្នុងសាលាទាំងនេះណាស់។ លោក ស្រី វីរៈ នាយកសាលាបឋមសិក្សាក្រូចដែលមានសិស្សភាគច្រើនជាជនជាតិដើមទំពួន បានបញ្ចេញចំណាប់អារម្មណ៍ថា "បណ្ណាល័យឌីជីថលនេះពិតជាបានផ្តល់ផលប្រយោជន៍ដល់គ្រូបង្រៀន សិស្ស ក៏ដូចជាដល់សហគមន៍មែនទែន។ កាលពីមុន សិស្សបឋមសិក្សាជាច្រើនមិនចង់មករៀនហើយឪពុកម្តាយរបស់ពួកគាត់ត្រូវតែបង្ខំពួកគាត់មកសាលាជារៀងរាល់ថ្ងៃ។ ប៉ុន្តែអ្វីៗបានផ្លាស់ប្តូរចាប់ពីពេលដែលមានបណ្ណាល័យនេះនៅក្នុងសាលា បណ្ណាល័យនេះបានទាក់ទាញឲ្យសិស្សមករៀនបានទៀងទាត់ជាងមុន និងបានជួយជំរុញឲ្យពួកគាត់ចូលចិត្តការសិក្សា។ គ្រូជាច្រើនបាននិយាយថាសិស្សរបស់គាត់អាចរៀនឆាប់ចេះជាងមុននៅពេលដែលមានសម្ភារៈសិក្សាថ្មីទាំងនេះ។ ចំពោះឪពុកម្តាយវិញ ពួកគេបានកត់សម្គាល់ឃើញពីការប្រែប្រួលអត្តចរិតរបស់កូនចំពោះការសិក្សា ហើយពួកគាត់បានចាប់ផ្តើមចូលរួមសកម្មភាពសាលាបានច្រើនជាងមុន"។

AEA បានបង្កើតផែនការដំណើរការដ៏ច្នៃប្រឌិតមួយដើម្បីបង្កើននិរន្តរភាពរបស់គម្រោងនេះ។ គ្រូជាច្រើនត្រូវការសម្ភារៈអប់រំបន្ថែមដើម្បីពង្រឹងសមត្ថភាពបង្រៀនរបស់ពួកគាត់។ មាតិកាឌីជីថលវីដេអូ និង Infographic អាចជួយឲ្យសិស្សយល់បន្ថែមពីលើកម្មវិធីសិក្សាដែលមានស្រាប់។ គម្រោងនេះបានឧបត្ថម្ភទឹកប្រាក់ជំនួយចំនួន៥០%ក្នុងការទិញទូរស័ព្ទថាប្លែតសម្រាប់គ្រូបង្រៀននៅតាមសាលាគោលដៅ។ កម្មវិធីទូរស័ព្ទដែលផ្ទុកធនធានអប់រំជាច្រើន ត្រូវបានគេបញ្ចូលក្នុងទូរស័ព្ទថាប្លែត ទាំងនេះដើម្បីជាជំនួយដល់គ្រូក្នុងការបង្រៀនក៏ដូចជាសម្រាប់ពួកគាត់ស្វ័យសិក្សា។ លោកគ្រូ ហាន សុខហេង ជាគ្រូបង្រៀនថ្នាក់ទី៥នៅសាលាបឋមសិក្សារយ៉ាលើ នៅ

Find out more about Development Innovations' activities and services:
www.development-innovations.org

Telling Our Story
U.S. Agency for International Development
Washington, DC 20523-1000
http://stories.usaid.gov

ខេត្តមណ្ឌលគិរី បានបញ្ចេញមតិថា "ទូរស័ព្ទថាប្លេត ទាំងនេះមានផ្ទុកនូវសម្ភារៈសិក្សានិងបង្រៀនជាច្រើន។ បើសិនជាខ្ញុំទិញទូរស័ព្ទថាប្លេត ពីផ្សារដោយខ្លួនឯង ខ្ញុំប្រហែលជាត្រូវបង់តម្លៃពេញ ហើយវាប្រហែលជាមិនមានកម្មវិធីច្រើនដូច ទូរស័ព្ទថាប្លេតទាំងនេះទេ។"

AEA ធ្លាប់ទទួលបានជោគជ័យក្នុងការបង្កើតឧបករណ៍និងប្រព័ន្ធជួយដល់គ្រូបង្រៀនជាភាសាខ្មែរនៅក្នុងកម្មវិធី Khmer រៀនអាន។ ឥឡូវនេះដោយមានជំនួយមូលនិធិពីគម្រោង Development Innovations ពួកគាត់បានជួយទៅដល់ប្រជាជនជនជាតិដើមភាគតិចនៅខេត្តមណ្ឌលគិរីនិងរតនគិរី ដែលក្នុងនោះមានគ្រូបង្រៀនជាង៩០នាក់ និងសិស្សជិត២០០០នាក់។ នាថ្ងៃអនាគត AEA សង្ឃឹមថានឹងជួយពង្រឹងសមត្ថភាពសហគមន៍ទាំងនេះ ដើម្បីប្រើប្រាស់និងថែរក្សាឧបករណ៍ទាំងនេះជាទ្រព្យសម្បត្តិរួម។ ទស្សនៈវិស័យរបស់ពួកគាត់គឺអាចអោយអ្នកបង្កើតមាតិកាអប់រំទាំងឡាយអាចប្រើប្រាស់មធ្យោបាយតែមួយដើម្បីផ្សព្វផ្សាយកិច្ចសហការនិងកាត់បន្ថយភាពលើសលប់នៃការងារ ។